ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផ្សារមូលបត្រកម្ពុជា
CSX
ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

លេខ: ០៦៩/២៥

ថ្ងៃ ព្រហ - ៧ រោច ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មីនា ឆ្នាំ ២០២៥

# សេចក្តីប្រកាសព័ត៌មាន

## ការចុះបញ្ជីលក់សញ្ញាបណ្ណធម្មតា (សញ្ញាបណ្ណបន្ទាប់បន្សំ) ជាផ្លូវការរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅផ្សារមូលបត្រកម្ពុជា

នាព្រឹកថ្ងៃព្រហស្បតិ៍ ៧រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥ ផ្សារមូលបត្រកម្ពុជា(ផមក) មានកិត្តិយស សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា សញ្ញាបណ្ណធម្មតារបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ត្រូវបានចុះបញ្ជីលក់ជាផ្លូវការ នៅផ្សារមូលបត្រកម្ពុជា។

ធនាគារ អេស៊ីលីដា ភីអិលស៊ី បានធ្វើការបោះផ្សាយលក់សញ្ញាបណ្ណធម្មតា (សញ្ញាបណ្ណបន្ទាប់បន្សំ) សម្រាប់វិនិយោគិនគុណវុឌ្ឍិលើកទី១ និងបានចុះបញ្ជីនៅផមក កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥ កន្លងទៅនេះ ជាមួយនឹងទឹកប្រាក់កៀរគរពីវិនិយោគិនគុណវុឌ្ឍិសរុបប្រមាណជា ៣៤៣,៣៥ ប៊ីលានរៀល (ប្រមាណ ៨៥,៨ លានដុល្លារអាមេរិក) និងបោះផ្សាយ ចុះបញ្ជីលក់សញ្ញាបណ្ណសាធារណៈលើកទី២ ដែលមានឈ្មោះថា “**សញ្ញាបណ្ណបន្ទាប់បន្សំរបស់ធនាគារ អេស៊ីលីដា ២**”នៅថ្ងៃនេះ ក្នុងទំហំបោះផ្សាយសរុបប្រមាណ ៥៦,៦៥ ប៊ីលានរៀល (ប្រមាណ ១៤,១៦លានដុល្លារអាមេរិក) និងតម្លៃចារឹក ១០០.០០០រៀល ក្នុងមួយឯកតា។ សញ្ញាបណ្ណនេះមាន ឥណប្រតិទានចំនួន៧ឆ្នាំ (២០២៥-២០៣២) ជាមួយអត្រាគូប៉ុង ៨.៥០%ក្នុងមួយឆ្នាំ និងទូទាត់ការប្រាក់រៀងរាល់ត្រីមាស។ ចំពោះសញ្ញាបណ្ណនេះ រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក បានផ្តល់ចំណាត់ថ្នាក់ឥណទាន “khAA”ដែលបង្ហាញក្នុងបរិបទកម្ពុជានូវ “សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ”។ គួររំលឹកផងដែរថា ចំនួនទឹកប្រាក់សរុប ដែលក្រុមហ៊ុនបានកៀរគរទាំងពីរលើកនេះមានចំនួន ១០០លានដុល្លារអាមេរិក នឹងអនុញ្ញាតឱ្យក្រុមហ៊ុនប្រើប្រាស់សម្រាប់ទុនបង្វិល សកម្មភាពធនាគារទូទៅ និងគោលដៅសាជីវកម្មផ្សេងៗទៀត ព្រមទាំងការធ្វើហិរញ្ញប្បទានឡើងវិញលើកម្ចីដែលមានស្រាប់ និង/ ឬ ការធ្វើហិរញ្ញប្បទានឡើងវិញលើកម្ចីបន្ទាប់បន្សំផ្សេងទៀត។

ផ្សារមូលបត្រកម្ពុជា

Cambodia Securities Exchange

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង÷
ទូរសព្ទ÷ ០២៣ ៩៥៨ ៨៨៨
អ៊ីម៉ែល ÷ listing@csx.com.kh